# ឯតទគ្គបាលី-ប្រែ (បិដកលេខ ៤០ ទំព័រ ៥៣-៥៨)

## (សម្រាប់សូត្រ)



រៀបរៀងដោយព្រះមហាសារត្ថធម្មោ នួន សារ៉េត ព.ស២៥៦៦, គ.ស២០២២

# ឯតទគ្គបុគ្គល

(បិដកលេខ ៤០ ,ទំព័រ ៥៣-៥៨)

*-ឯតទគ្គំ ភិក្ខវេ មម សាវកានំ ភិក្ខូនំ :

១-រត្តញ្ញូនំ យទិទំ អញ្ញាកោណ្ឌញ្ញោ ។

២-មហាបញ្ញានំ យទិទំ សារីបុត្តោ ។

៣-ឥទ្ធិមន្តានំ យទិទំ មហាមោគ្គល្លានោ ។

៤-ធុតវាទានំ យទិទំ មហាកស្សបោ ។

៥-ទិព្វចក្ខុកានំ យទិទំ អនុរុទ្ធោ ។

៦-ឧច្ចាកុលិកានំ យទិទំ ភទ្ទិយោ កាឡិគោធាយ-បុត្តោ ។

៧-មញ្ជុស្សរានំ យទិទំ លកុណ្ឌកភទ្ទិយោ ។

៨-សីហនាទិកានំ យទិទំ បិណ្ឌោលភារទ្វាជោ ។

៩-ធម្មកថិកានំ យទិទំ បុណ្ណោ មន្តានីបុត្តោ ។

១០-សង្ខិត្តេន ភាសិតស្ស វិត្ថារេន អត្ថំ វិភជន្តានំ យទិទំ មហាកច្ចានោតិ ៕

វគ្គោ បឋមោ ៕

*_ឯតទគ្គំ ភិក្ខវេ មម សាវកានំ ភិក្ខូនំ :

១_មនោមយំ កាយំ អភិនិម្មិនន្តានំ យទិទំ ចុល្ល-បន្ថកោ ។ ចេតោវិវដ្ដកុសលានំ យទិទំ ចុល្លបន្ថកោ ។

២_បញ្ញាវិវដ្ដកុសលានំ យទិទំ មហាបន្ថកោ ។

៣_អរណវិហារីនំ យទិទំ សុភូតិ ។ ទក្ខិណេយ្យានំ យទិទំ សុភូតិ ។

៤_អារញ្ញកានំ យទិទំ រេវតោ ខទិរវនិយោ ។

៥_ឈាយីនំ យទិទំ កង្ខារេវតោ ។

៦_អារទ្ធវីរិយានំ យទិទំ សោណោ កោឡិវិសោ ។

៧_កល្យាណវាក្ករណានំ យទិទំ សោណោ កុដិ-កណ្ណោ ។

៨_លាភីនំ យទិទំ សីវលី ។

៩_សទ្ធាធិមុត្តានំ យទិទំ វក្កលីតិ ។

វគ្គោ ទុតិយោ ២

*_ឯតទគ្គំ ភិក្ខវេ មម សាវកានំ ភិក្ខូនំ :

១_សិក្ខាកាមានំ យទិទំ រាហុលោ ។

២_សទ្ធាបព្វជិតានំ យទិទំ រដ្ឋបាលោ ។

៣-បឋមំ សលាកំ គណ្ហន្តានំ យទិទំ កុណ្ឌធានោ ។

៤-បដិភាណវន្តានំ យទិទំ វង្គីសោ ។

៥-សមន្តប្បាសាទិកានំ យទិទំ ឧបសេនោ វង្គន្ត-
បុត្តោ ។

៦-សេនាសនប្បញ្ញាបកានំ យទិទំ ទព្វោ មល្ល-
បុត្តោ ។

៧-ទេវតានំ បិយមនាបានំ យទិទំ បិលិន្ទវច្ឆោ ។

៨-ខិប្បាភិញ្ញានំ យទិទំ ពាហិយោ ទារុចីរិយោ ។

៩-ចិត្តកថិកានំ យទិទំ កុមារកស្សបោ ។

១០-បដិសម្ភិទប្បត្តានំ យទិទំ មហាកោដ្ឋិតោតិ ។

វគ្គោ តតិយោ ៕

*-ឯតទគ្គំ ភិក្ខវេ មម សាវកានំ ភិក្ខូនំ ៖

១-ពហុស្សុតានំ យទិទំ អានន្ទោ ។ សតិមន្តានំ យទិទំ អានន្ទោ ។ គតិមន្តានំ យទិទំ អានន្ទោ ។ ធិតិមន្តានំ យទិទំ អានន្ទោ ។ ឧបដ្ឋាកានំ យទិទំ អានន្ទោ ។

២-មហាបរិសានំ យទិទំ ឧរុវេលកស្សបោ ។

៣‐កុលប្បសាទកានំ យទិទំ កាឡុទាយិ ។

៤‐អប្បាពាធានំ យទិទំ ពក្កុលោ ។

៥‐បុព្វេនិវាសំ អនុស្សរន្តានំ យទិទំ សោភិតោ ។

៦‐វិនយធរានំ យទិទំ ឧបាលិ ។

៧‐ភិក្ខុនោវាទកានំ យទិទំ នន្ទកោ ។

៨‐ឥន្ទ្រិយេសុ គុត្តទ្វារានំ យទិទំ នន្ទោ ។

៩‐ភិក្ខុឱវាទកានំ យទិទំ មហាកប្បិនោ ។

១០‐តេជោធាតុកុសលានំ យទិទំ សាគតោ ។

១១‐បដិភាណេយ្យកានំ យទិទំ រាធោ ។

១២‐លូខចីវរធរានំ យទិទំ មោឃរាជាតិ ។

វគ្គោ ចតុត្ថោ ៤

*‐ឯតទគ្គំ ភិក្ខវេ មម សាវិកានំ ភិក្ខុនីនំ ៖

១‐រត្តញ្ញូនំ យទិទំ មហាបជាបតី គោតមី ។

២‐មហាបញ្ញានំ យទិទំ ខេមា ។

៣‐ឥទ្ធិមន្តីនំ យទិទំ ឧប្បលវណ្ណា ។

៤‐វិនយធរានំ យទិទំ បដាចារា ។

៥‐ធម្មកថិកានំ យទិទំ ធម្មទិន្នា ។

៦_ឈាយីនីនំ យទិទំ នន្ទា ។

៧_អារទ្ធវីរិយានំ យទិទំ សោណា ។

៨_ទិព្វចក្ខុកានំ យទិទំ សកុលា ។

៩_ខិប្បាភិញ្ញានំ យទិទំ ភទ្ទា កុណ្ឌលកេសា ។

១០_បុព្វេនិវាសំ អនុស្សរន្តីនំ យទិទំ ភទ្ទា កបិលានី ។

១១_មហាភិញ្ញាបត្តានំ យទិទំ ភទ្ទា កច្ចានា ។

១២_លូខចីវរធរានំ យទិទំ កិសាគោតមី ។

១៣_សទ្ធាធិមុត្តានំ យទិទំ សិគាលមាតាតិ ។

វគ្គោ បញ្ចមោ ៥

*_ឯតទគ្គំ ភិក្ខវេ មម សាវកានំ ឧបាសកានំ :

១_បឋមំ សរណំ គច្ឆន្តានំ យទិទំ តបុស្សភល្លិកា វាណិជា ។

២_ទាយកានំ យទិទំ សុទត្តោ គហបតិ អនាថ-បិណ្ឌិកោ ។

៣_ធម្មកថិកានំ យទិទំ ចិត្តោ គហបតិ មច្ឆិក-សណ្ឌិកោ ។

៤_ចតូហិ សង្គហវត្ថូហិ បរិសំ សង្គណ្ហន្តានំ យទិទំ

ហត្ថកោ អាឡវកោ ។

៥_បណីតទាយកានំ យទិទំ មហានាមោ សក្កោ ។

៦_មនាបទាយកានំ យទិទំ ឧគ្គោ គហបតិ វេសាលិកោ ។

៧_សង្ឃុបដ្ឋាកានំ យទិទំ ឧគ្គតោ គហបតិ ។

៨_អវេច្ចប្បសន្នានំ យទិទំ សូរោ អម្ពដ្ឋោ ។

៩_បុគ្គលប្បសន្នានំ យទិទំ ជីវកោ កោមារភច្ចោ ។

១០_វិស្សាសកានំ យទិទំ នកុលបិតា គហបតីតិ ។

វគ្គោ ឆដ្ឋោ ៦

*_ឯតទគ្គំ ភិក្ខវេ មម សាវិកានំ ឧបាសិកានំ :

១_បឋមំ សរណំ គច្ឆន្តីនំ យទិទំ សុជាតា សេនានិធីតា។

២_ទាយិកានំ យទិទំ វិសាខា មិគារមាតា ។

៣_ពហុស្សុតានំ យទិទំ ខុជ្ជុត្តរា ។

៤_មេត្តាវិហារិនីនំ យទិទំ សាមាវតី ។

៥_ឈាយិនីនំ យទិទំ ឧត្តរា នន្ទមាតា ។

៦. បណីតទាយិកានំ យទិទំ សុប្បវាសា កោលិយធីតា ។

៧. គិលានុបដ្ឋាកីនំ យទិទំ សុប្បិយា ឧបាសិកា ។

៨. អវេច្ចប្បសន្នានំ យទិទំ កាតិយានី ។

៩. វិស្សាសិកានំ យទិទំ នកុលមាតា គហបតានី ។

១០. អនុស្សវប្បសន្នានំ យទិទំ កាឡី ឧបាសិកា កុររឃរិកាតិ ។

វគ្គោ សត្តមោ ៗ

# ឯតទគ្គបាលិ

[១៤៦] ម្នាលភិក្ខុទាំងឡាយ បណ្តាពួកភិក្ខុអ្នកដឹងរាត្រី ដែលជាសាវករបស់តថាគត ស្រេចនឹងអញ្ញាកោណ្ឌញ្ញៈប្រសើរជាងគេ ។ បណ្តាពួកភិក្ខុអ្នកមានប្រាជ្ញាច្រើនស្រេចនឹងសារីបុត្ត ។ ពួកភិក្ខុអ្នកមានឫទ្ធិស្រេចនឹងមហាមោគ្គល្លាន ។ ពួកភិក្ខុអ្នកពោលពាក្យកម្ចាត់បង់កិលេសស្រេចនឹងមហាកស្សបៈ ។ ពួកភិក្ខុអ្នកមានទិព្វចក្ខុស្រេចនឹងអនុរុទ្ធ ។ ពួកភិក្ខុអ្នកមានត្រកូលខ្ពស់ ស្រេចនឹងកទ្ទិយកាឡិគោធាយ-បុត្ត ។ ពួកភិក្ខុអ្នកមានសំឡេងពីរោះស្រេចនឹងលកុណ្ឌកភទ្ទិយៈ ។ ពួកភិក្ខុអ្នកបន្លឺសីហនាទស្រេចនឹងបិណ្ឌោលភារទ្វាជៈ ។ ពួកភិក្ខុជាធម្ម-កថិក ស្រេចនឹងបុណ្ណមន្តានីបុត្ត ។ ពួកភិក្ខុអ្នកចែកសេចក្តីធម៌ដែលតថាគតសម្តែងដោយសង្ខេបឲ្យពិស្តារបាន ស្រេចនឹងមហាកច្ចានៈ ។

ចប់ វគ្គទី ១ ។

[១៤៧] ម្នាលភិក្ខុទាំងឡាយ បណ្តាពួកភិក្ខុអ្នកនិម្មិតកាយសម្រេចតាមចិត្តបាន ដែលជាសាវ័ករបស់តថាគត ស្រេចនឹងចុល្លបន្ថកៈប្រសើរជាងគេ ។ ពួកភិក្ខុអ្នកឈ្លាសក្នុងការបើកចិត្ត ស្រេចនឹងចុល្ល-បន្ថកៈ ។ ពួកភិក្ខុអ្នកឈ្លាសក្នុងការបើកប្រាជ្ញា ស្រេចនឹងមហាបន្ថកៈ ។

ពួកភិក្ខុអ្នកនៅដោយឥតកិលេស ស្រេចនឹងសុភូតិ ។ ពួកភិក្ខុអ្នកគួរដល់ទក្ខិណាទាន ស្រេចនឹងសុភូតិ ។ ពួកភិក្ខុអ្នកនៅក្នុងព្រៃ ស្រេចនឹងរេវតខទិរវនិយៈ ។ ពួកភិក្ខុអ្នកបានឈាន ស្រេចនឹងកង្ខារេវតៈ ។ ពួកភិក្ខុអ្នកមានព្យាយាមបរិបូណ៌ ស្រេចនឹងសោណកោលិវិសៈ ។ ពួកភិក្ខុអ្នកពោលពាក្យពីរោះ ស្រេចនឹងសោណកុដិកណ្ណៈ ។ ពួកភិក្ខុអ្នកមានលាភ ស្រេចនឹងសីវលី ។ ពួកភិក្ខុអ្នកមានសទ្ធាស៊ប់ ស្រេចនឹងវក្កលិ ។

ចប់ វគ្គទី ២ ។

[១៤៨] ម្នាលភិក្ខុទាំងឡាយ បណ្តាពួកភិក្ខុអ្នកស្រឡាញ់សិក្ខាដែលជាសាវ័ករបស់តថាគត ស្រេចនឹងរាហុលប្រសើរជាងគេ ។ ពួកភិក្ខុអ្នកបួសដោយសទ្ធា ស្រេចនឹងរដ្ឋបាល ។ ពួកភិក្ខុអ្នកចាប់ស្លាកជំបូងបង្អស់ ស្រេចនឹងកុណ្ឌធាន ។ ពួកភិក្ខុអ្នកមានបដិភាណ ស្រេចនឹងវង្គីសៈ ។ ពួកភិក្ខុអ្នកមានសេចក្តីជ្រះថ្លាគ្រប់គ្រាន់ ស្រេចនឹងឧបសេនវង្គន្តបុត្ត ។ ពួកភិក្ខុអ្នកក្រាលសេនាសនៈ ស្រេចនឹងទព្វមល្លបុត្ត ។ ពួកភិក្ខុជាទីស្រឡាញ់ ជាទីគាប់ចិត្តរបស់ទេវតាទាំងឡាយ ស្រេចនឹងបិលិន្ទវច្ឆៈ ។ ពួកភិក្ខុអ្នកត្រាស់ដឹងរហ័ស ស្រេចនឹងពាហិយទារុចីរិយៈ ។ ពួកភិក្ខុអ្នកចេះសម្តីវិចិត្ត ស្រេចនឹងកុមារកស្សបៈ ។ ពួកភិក្ខុអ្នកបានបដិសម្ភិទា ស្រេចនឹងមហាកោដ្ឋិតៈ ។

ចប់ វគ្គទី ៣ ។

[១៤៩] ម្នាលភិក្ខុទាំងឡាយ បណ្តាពួកភិក្ខុអ្នកចេះដឹងច្រើន ដែលជាសាវ័ករបស់តថាគត ស្រេចនឹងអានន្ទប្រសើរជាងគេ ។ ពួកភិក្ខុអ្នកមានស្មារតីស្រេចនឹងអានន្ទ ។ ពួកភិក្ខុអ្នកមានគតិ ស្រេចនឹងអានន្ទ ។ ពួកភិក្ខុអ្នកមានប្រាជ្ញា ស្រេចនឹងអានន្ទ ។ ពួកភិក្ខុជាឧបដ្ឋាកក៏ស្រេចនឹងអានន្ទដែរ ។ ពួកភិក្ខុអ្នកមានបរិស័ទច្រើន ស្រេចនឹងឧរុវេលកស្សប: ។ ពួកភិក្ខុអ្នកញុាំងត្រកូលឲ្យជ្រះថ្លា ស្រេចនឹងកាឡុទាយិ ។ ពួកភិក្ខុអ្នកគ្មានអាពាធ ស្រេចនឹងពក្កុល: ។ ពួកភិក្ខុអ្នករឭកឃើញបុព្វេនិវាស ស្រេចនឹងសោភិត: ។ ពួកភិក្ខុអ្នកទ្រទ្រង់វិន័យ ស្រេចនឹងឧបាលិ ។ ពួកភិក្ខុអ្នកឲ្យឱវាទភិក្ខុនី ស្រេចនឹងនន្ទក: ។ ពួកភិក្ខុអ្នករក្សាទ្វារក្នុងឥន្ទ្រិយទាំងឡាយ ស្រេចនឹងនន្ទ: ។ ពួកភិក្ខុអ្នកឲ្យឱវាទភិក្ខុ ស្រេចនឹងមហាកប្បិន ។ ពួកភិក្ខុអ្នកឈ្លាសវៃក្នុងតេជោធាតុ ស្រេចនឹងសាគត: ។ ពួកភិក្ខុអ្នកឈ្លាសវៃក្នុងបដិភាណ ស្រេចនឹងរាធ: ។ ពួកភិក្ខុអ្នកទ្រទ្រង់ចីវរសៅហ្មង ស្រេចនឹងមោឃរាជ ។

ចប់ វគ្គ ទី ៤ ។

[១៥០] ម្នាលភិក្ខុទាំងឡាយ បណ្តាពួកភិក្ខុនីអ្នកដឹងរាត្រី ដែលជាសាវិការបស់តថាគត ស្រេចនឹងមហាបជាបតីគោតមីប្រសើរជាងគេ ។

ពួកភិក្ខុនីអ្នកមានប្រាជ្ញាច្រើន ស្រេចនឹងនាងខេមា ។ ពួកភិក្ខុនីអ្នកមានឫទ្ធិ ស្រេចនឹងនាងឧប្បលវណ្ណា ។ ពួកភិក្ខុនីអ្នកទ្រទ្រង់វិន័យ ស្រេចនឹងនាងបដាចារ ។ ពួកភិក្ខុនីជាធម្មកថិកា ស្រេចនឹងនាងធម្មទិន្នា ។ ពួកភិក្ខុនីអ្នកមានឈាន ស្រេចនឹងនាងនន្ទា ។ ពួកភិក្ខុនីអ្នកមានព្យាយាមបរិបូណ៌ ស្រេចនឹងនាងសោណា ។ ពួកភិក្ខុនីអ្នកមានទិព្វចក្ខុ ស្រេចនឹងនាងសកុលា ។ ពួកភិក្ខុនីបានត្រាស់ដឹងរហ័ស ស្រេចនឹងនាងភទ្ទាកុណ្ឌលកេសា ។ ពួកភិក្ខុនីអ្នករឭកឃើញបុព្វេនិវាស ស្រេចនឹងនាងភទ្ទាកបិលានី ។ ពួកភិក្ខុនីអ្នកបានអភិញ្ញាដ៏ធំ ស្រេចនឹងភទ្ទាកច្ចានា ។ ពួកភិក្ខុនីអ្នកទ្រទ្រង់ចីវរដ៏សៅហ្មង ស្រេចនឹងនាងកិសាគោតមី ។ ពួកភិក្ខុនីអ្នកមានសទ្ធាស៊ប់ ស្រេចនឹងនាងសិគាលមាតា ។

ចប់ វគ្គទី ៥ ។

[១៥១] ម្នាលភិក្ខុទាំងឡាយ បណ្ដាពួកឧបាសកអ្នកដល់សរណៈជាបឋម ដែលជាសាវ័ករបស់តថាគត ស្រេចនឹងតបុស្សពាណិជនិងភល្លិកពាណិជប្រសើរជាងគេ ។ ពួកឧបាសកជាទាយក (អ្នកឲ្យទាន) ស្រេចនឹងសុទត្តគហបតី គឺអនាថបិណ្ឌិកសេដ្ឋី ។ ពួកឧបាសកជាធម្មកថិក ស្រេចនឹងចិត្តគហបតី ដែលនៅក្នុងស្រុកមច្ឆិកសណ្ឌៈ ។

ពួកឧបាសកអ្នកសង្គ្រោះបរិស័ទដោយសង្គហវត្ថុ ៤ ប្រការ ស្រេចនឹងហត្ថកអាឡវក ។ ពួកឧបាសកអ្នកឲ្យភោជនមានរសដ៏ឧត្តម ស្រេចនឹងមហានាមសក្កៈ ។ ពួកឧបាសកអ្នកឲ្យភោជនជាទីគាប់ចិត្ត ស្រេចនឹងឧគ្គគហបតី អ្នកនៅក្នុងក្រុងវេសាលី ។ ពួកឧបាសកអ្នកបម្រើសង្ឃ ស្រេចនឹងឧគ្គតគហបតី ។ ពួកឧបាសកអ្នកជ្រះថ្លាមិនកម្រើក ស្រេចនឹងសូរអម្ពដ្ឋ ។ ពួកឧបាសកអ្នកញុំាងបុគ្គលឲ្យជ្រះថ្លា ស្រេចនឹងជីវកកោមារភច្ច ។ ពួកឧបាសកអ្នកពេះនិយាយឲ្យអ្នកដទៃស្និទ្ធស្នាល ស្រេចនឹងនកុលបិតាគហបតី ។

ចប់ វគ្គទី ៦ ។

[១៥២] ម្នាលភិក្ខុទាំងឡាយ បណ្តាពួកឧបាសិកាអ្នកដល់នូវសរណៈជាបឋម ដែលជាសាវិការបស់តថាគត ស្រេចនឹងនាងសុជាតា សេនានិធីតា[១] ប្រសើរជាងគេ ។ ពួកឧបាសិកាជាទាយិកា (អ្នកឲ្យទាន) ស្រេចនឹងនាងវិសាខាមិគារមាតា ។ ពួកឧបាសិកាអ្នកពេះដឹងច្រើន ស្រេចនឹងនាងខុជ្ជុត្តរា ។ ពួកឧបាសិកាអ្នកនៅដោយមេត្តា ស្រេចនឹងនាងសាមាវតី ។ ពួកឧបាសិកាអ្នកមានឈាន ស្រេចនឹងនាងឧត្តរានន្ទមាតា ។ ពួកឧបាសិកាអ្នកឲ្យទានថ្លិតថ្លង់ ស្រេចនឹងនាងសុប្បវាសាកោលិយធីតា ។ ពួកឧបាសិកាអ្នកបម្រើជំងឺ ស្រេចនឹងនាងសុប្បិយាឧបាសិកា ។

១ អដ្ឋកថា ថា សេនីយធីតា ។

*ពួកឧបាសិកាអ្នកជ្រះថ្លាមិនកម្រើក ស្រេចនឹងនាងកាតិយានី ។ ពួកឧបាសិកាអ្នកចេះធ្វើឲ្យអ្នកដទៃស្និទ្ធស្នាល ស្រេចនឹងនាងនកុលមាតាគហបតានី ។ ពួកឧបាសិកាអ្នកជ្រះថ្លាតាមពាក្យដែលឮតៗ គ្នា ស្រេចនឹងកាលីឧបាសិកាកុររឃរិកា[១] ។*

ចប់ វគ្គទី ៧ ។

---

១. កុលឃរិកា ។



រៀបរៀងដោយព្រះមហាសារត្ថធម្មោ នួន សារ៉េត ព.ស២៥៦៦, គ.ស២០២២